**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥១ ០១៨ ៥៨៥ ពាគស

*ថ្ងៃអង្គារ ២កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨*

# សេចក្ដីប្រកាសព័ត៌មាន

កាលពីថ្ងៃអង្គារ ២កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ នៅធនាគារជាតិនៃកម្ពុជា ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បាន អនុញ្ញាតឱ្យគណៈប្រតិភូការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ដឹកនាំដោយ លោកស្រីបណ្ឌិត Junhong Chang ប្រធានការិយាល័យ AMRO ចូលជួបសម្ដែងការគួរសមនិង ជម្រាបជូនពីលទ្ធផលនៃបេសកកម្មតាមដានស្ថានភាពសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ២០១៨ ដែលបាន ធ្វើឡើងចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨។

ជាកិច្ចចាប់ផ្ដើម ក្នុងនាមការិយាល័យ AMRO លោកស្រីបណ្ឌិត Junhong Chang បាន សម្ដែងការអបអរសាទរចំពោះរាជរដ្ឋាភិបាលថ្មីដែលត្រូវបានបង្កើតឡើងពីការបោះឆ្នោតសកលកាល ពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ប្រកបដោយតម្លាភាព សេរី ពហុបក្ស និងយុត្តិធម៌ ជាមួយនឹងចំនួន ប្រជាជនចូលរួមបោះឆ្នោតយ៉ាងច្រើនលើសលប់។ លោកស្រីក៏បានគូសបញ្ជាក់ថា ស្ថិរភាពនយោបាយ ជាកត្តាមូលដ្ឋាននៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងការបន្តជំរុញកំណើនសេដ្ឋកិច្ចឱ្យកើនឡើង ប្រកបដោយចីរភាព។

ចំពោះស្ថានភាពសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ ការិយាល័យ AMRO បានវាយតម្លៃខ្ពស់ថា កម្ពុជានឹងអាចទទួលបានកំណើនក្នុងអត្រា ៧,២% ខ្ពស់ជាងឆ្នាំ២០១៧ (៧%)។ កំណើនខ្ពស់នេះ គាំទ្រដោយកំណើនរឹងមាំក្នុងវិស័យសំណង់ កំណើនខ្ពស់ក្នុងវិស័យកាត់ដេរនិងទេសចរណ៍។ ទន្ទឹមនេះ ការកើនឡើងចំណាយរបស់រាជរដ្ឋាភិបាល ដូចជាទៅលើការបង្កើនប្រាក់បៀវត្សរ៍និង ការវិនិយោគសាធារណៈក៏រួមចំណែកជំរុញកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០១៨ ផងដែរ។ ចំណែកឯអត្រា អតិផរណារំពឹងថានឹងបន្តស្ថិតក្នុងកម្រិតទាបប្រមាណ ៣,១%។ ទុនបម្រុងអន្តរជាតិបន្តកើនឡើង ជាលំដាប់ ដល់ប្រមាណ ១០ ប៊ីលានដុល្លារអាមេរិក នៅចុងឆ្នាំ២០១៨ ដែលអាចធានាលើការទូទាត់ ការនាំចូលទំនិញនិងសេវាបានប្រមាណ ៦ខែ។ ម្យ៉ាងទៀត សូចនាករក្នុងវិស័យហិរញ្ញវត្ថុបាន



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

បង្ហាញស្ថានភាពល្អប្រសើរ ក្នុងស្ថានភាពដែលឥណទានទៅកាន់វិស័យឯកជនស្ថិតក្នុងកម្រិតសមស្រប។

ដើម្បីរក្សាបានកំណើនរឹងមាំប្រកបដោយចីរភាព ការិយាល័យ AMRO បានផ្តល់អនុសាសន៍ដល់កម្ពុជាឱ្យបន្តកិច្ចខំប្រឹងប្រែងនិងពន្លឿនការកែទម្រង់រចនាសម្ព័ន្ធ រក្សាស្ថិរភាពហិរញ្ញវត្ថុ បន្តគរពូនទុនបម្រុងអន្តរជាតិ ផ្តល់អាទិភាពធនធានសារពើពន្ធលើការចំណាយដែលជួយជំរុញកំណើន និងពង្រឹងភាពប្រកួតប្រជែង។

ជាការឆ្លើយតប ឯកឧត្តម ទេសាភិបាល បានថ្លែងអំណរគុណដល់គណៈប្រតិភូការិយាល័យ AMRO ដែលបានសម្តែងការអបអរសាទរនិងបន្តគាំទ្រដល់រាជរដ្ឋាភិបាលថ្មី និងបានមកបំពេញបេសកកម្មនៅកម្ពុជា។ ឯកឧត្តម ទេសាភិបាល បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃបេសកកម្មរបស់ការិយាល័យ AMRO ដែលបានជួយតាមដានស្ថានភាពសេដ្ឋកិច្ចនិងផ្តល់អនុសាសន៍សម្រាប់ការបន្តអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ ឯកឧត្តម ទេសាភិបាល ក៏បានស្នើសុំការិយាល័យ AMRO បន្តជួយអភិវឌ្ឍសមត្ថភាពធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជាតាមរយៈការផ្តល់ជំនួយបច្ចេកទេស និងបន្តផ្តល់ឱកាសឱ្យមន្ត្រីធនាគារជាតិនៃកម្ពុជាហាត់ការងារ (Secondee) នៅការិយាល័យ AMRO នាពេលខាងមុខថែមទៀត។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh